**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ ០៤៤/២៣.............អអរ**

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ចាម»

រសៀលថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ចាម»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម អ៊ុន ចាន់ដា អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម**
- **រួមទាំងមន្ទីរជំនាញជុំវិញរដ្ឋបាលខេត្តកំពង់ចាម**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកំពង់ចាម ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## I. សេចក្តីផ្តើម

ខេត្តកំពង់ចាម បែងចែកចេញជា ក្រុង១ ៩ស្រុក និងក្រុង១ មាន១០៥ឃុំ និងសង្កាត់៤ និង៩២៣ភូមិ ដែលមានប្រជាជនរស់នៅសរុបចំនួន ១.១៣៤.២២១នាក់ ស្រីចំនួន ៥៧៥.៣៥៨នាក់ ស្មើនឹង ២៨៤.៣៨៩គ្រួសារ សក្តានុពលសេដ្ឋកិច្ចរបស់ខេត្តកំពង់ចាមពឹងផ្អែកលើវិស័យសំខាន់ៗ៣គឺ វិស័យកសិកម្ម សេវាកម្ម និងវិស័យឧស្សាហកម្ម ដែលក្នុងនោះ ប្រជាពលរដ្ឋប្រកបរបរកសិកម្មជាចម្បងស្មើនឹង ៦៣,៩៣%, ឧស្សាហកម្ម និងសិប្បកម្ម ០,៦៩% និងរបរសេវាកម្ម ៣៥,៣៨%។ ទំហំសេដ្ឋកិច្ចសរុបរបស់ខេត្តប្រមាណ ១.៨០៥លានដុល្លា ស្មើនឹង៦,៧% នៃសេដ្ឋកិច្ចជាតិសរុប ចំណូលសម្រាប់មនុស្សម្នាក់មានចំនួន ១.៥៩២ដុល្លា។

## II. សមិទ្ធផលសំខាន់ៗ

សមិទ្ធផលសំខាន់ៗ ដែលខេត្តសម្រេចបានរួមមានៈ

- **វិស័យគាំពារសង្គមៈ** រដ្ឋបាលខេត្ត បាននូវគោលនយោបាយគាំពារសង្គម សំដៅជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដែលមានហានិភ័យខ្ពស់ សំដៅកាត់បន្ថយភាពក្រីក្រឱ្យបានជាអតិបរិមា ដែលក្នុងនោះ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ បានអនុវត្តចំនួន ១៦,១៩៤ករណី ចំណាយថវិកា ៤,១៦៣,៦៨០,០០០រៀល, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានអនុវត្តចំពោះគ្រួសារក្រីក្រ ៤៨,៣៥៤គ្រួសារ ស្មើនឹងទឹកប្រាក់ ២៣៩,១៦៣,៩៦៤,០០០រៀល, កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារដែលមានអ្នកឆ្លង និងស្លាប់ ដោយជំងឺកូវីដ-១៩ សរុបចំនួន ៧៦០គ្រួសារ ចំណាយថវិកា ១៣២,៤៨៤,៩០០រៀល, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេល មានសម្ពាធអតិផរណាចំនួន ១១,៩៥៨នាក់ ស្មើនឹងទឹកប្រាក់ ១,៥៦៩,៧០១,៤០០រៀល និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ដោយទឹកជំនន់ចំនួន ៨,១៧៩នាក់ ស្មើនឹងទឹកប្រាក់ ១,២៣៤,៩៦០.០០០រៀល។
- **វិស័យកសិកម្មៈ** វិស័យកសិកម្មបានរួមចំណែកក្នុងសេដ្ឋកិច្ចខេត្តទាំងមូល ប្រមាណជាង ៤០%។ រដ្ឋបាលខេត្ត បានខិតខំជំរុញនូវយន្តការអភិវឌ្ឍវិស័យកសិកម្មនេះ ដូចជា ការអប់រំ បណ្តុះបណ្តាលបច្ចេកទេសក្នុងការប្រើប្រាស់ជី ថ្នាំកសិកម្ម និងជំរុញនូវការប្រើប្រាស់ពូជប្រកបដោយគុណភាពដល់ប្រជាកសិករ ក្នុងគោលដៅបង្កើនទិន្នផល ធានាបាននូវសន្តិសុខស្បៀង លើកកម្ពស់សេដ្ឋកិច្ចគ្រួសារ កាត់បន្ថយភាពក្រីក្រ។ ក្នុងនោះ ការអនុវត្តដំណាំស្រូវ ដំណាំកសិ-ឧស្សាហកម្ម ផលិតកម្មសត្វ និងដំណាំរួមផ្សំផ្សេងទៀតមានកំណើនគួរកត់សម្គាល់។ ខេត្តក៏បានយកចិត្តទុកដាក់ក្នុងការកសាងនូវប្រព័ន្ធធារាសាស្ត្រ ក្នុងន័យទ្រទ្រង់នូវការផ្គត់ផ្គង់ទឹកទូទាំងខេត្តទាំងមូល ជាពិសេសក្នុងវិស័យកសិកម្ម ទប់ស្កាត់ហានិភ័យដែលបណ្តាលមកពីគ្រោះធម្មជាតិ ទឹកជំនន់ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋផ្ទាល់។ ដោយបច្ចុប្បន្ននេះ ខេត្តមានប្រព័ន្ធធារាសាស្ត្រសរុបចំនួន ២៤៨កន្លែង។
- **វិស័យសាធារណការ និងអភិវឌ្ឍន៍ជនបទៈ** ដោយមានការសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ទីរអភិវឌ្ឍន៍ជនបទ រដ្ឋបាលខេត្តបានសម្រេចបាននូវការស្ថាបនា និងជួសជុលថែទាំទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធទាំងនៅទីក្រុង និងជនបទ ដោយក្នុងនោះ ទូទាំងខេត្តគ្របដណ្តប់ដោយ ផ្លូវក្រាលកៅស៊ូ AC ចំនួន ១១ខ្សែ ប្រវែង ៩.៦០១ម៉ែត្រ ផ្លូវក្រាលកៅស៊ូ DBST ចំនួន ៣៤ខ្សែ ប្រវែង ៧២.១៩៨ម៉ែត្រ ផ្លូវបេតុង ៦០៨ខ្សែ ប្រវែង៣០៤.២៩៤ម៉ែត្រ និងផ្លូវ

ក្រាលគ្រួសក្រហម ១៤១ខ្សែ ប្រវែង ៤៥៤.៨០០ម៉ែត្រ។ ជាមួយគ្នានោះ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងអនាម័យជនបទ ក៏ត្រូវបានលើកកម្ពស់ ដោយបច្ចុប្បន្ននេះ នៅតាមខ្នងផ្ទះប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ មានចំនួន ១៩៩.៩៧៩ខ្នងផ្ទះ ស្មើនឹង ៩១,០១% និងមានថាមពលអគ្គិសនីគ្របដណ្តប់ទូទាំងខេត្តចំនួន ៩២១ភូមិ ស្មើនឹង ៩៩,៧៨% មានន័យថា នៅសល់តែ ២ភូមិទៀតប៉ុណ្ណោះ ដែលពុំទាន់មានអគ្គិសនីប្រើប្រាស់។

- **វិស័យទេសចរណ៍៖** ជាខេត្តដែលពោរពេញទៅដោយរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ វប្បធម៌ធម្មជាតិ រមណីយដ្ឋានកែច្នៃ និងមជ្ឈមណ្ឌលកំសាន្តជាច្រើនកន្លែង ភ្ញៀវទេសចរដែលបានមកកំសាន្តនៅខេត្តមានការកើនឡើងជាលំដាប់។ ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ នៅទូទាំងខេត្តកំពង់ចាម ទទួលបានភ្ញៀវមកទស្សនាកំសាន្តសរុបចំនួន ២.៥៥៧.៨៩៥នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិចំនួន ២.៥០៩.៣២៩នាក់ និងភ្ញៀវអន្តរជាតិ ៤៨.៥៧៥នាក់។

## III. សម្គាល់

រដ្ឋបាលខេត្តកំពង់ចាម បានយកចិត្តទុកដាក់ខ្ពស់ ក្នុងការអភិវឌ្ឍឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ទាំងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងសមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ជាពិសេស គឺការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយរដ្ឋបាលខេត្ត បានខិតខំស្រាវជ្រាវ ស្វែងរកផលិតផលដែលជាសក្តានុពលរបស់ខេត្ត ដើម្បីជំរុញនូវចលនា **"ភូមិ១ ផលិតផល១"** សំដៅបង្កើតការងារនៅមូលដ្ឋានផ្ទាល់ កាត់បន្ថយចំណាកស្រុក អភិវឌ្ឍន៍នូវចំណេះដឹង និងបច្ចេកទេសដល់ប្រជាពលរដ្ឋ លើកស្ទួយផលិតផលខ្មែរ ទាំងបរិមាណ និងគុណភាព ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ព្រមទាំងអាចទាក់ទាញភ្ញៀវទេសចរផងដែរ៕

ថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣